00347450



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 07 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ឆ្នាំ ២០០៧-អវតក/អជសដ
Case File/Dossier N° 001/18-07-2007-ECCC/TC

| | |
|---|---|
| ចំពោះមុខ | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ | ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩ |
| ប្រភេទឯកសារ | សាធារណៈ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 07 / JUL / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

# ដីកាកំណត់កាលវិភាគនៃដំណើរការសវនាការ (អង្គហេតុ និងលំដាប់នៃការកោះហៅសាក្សី) សម្រាប់រយៈពេលពីថ្ងៃទី ១៣ ខែកក្កដា ដល់ថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០០៩

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT

**ជនជាប់ចោទ**

កាំង ហ្កេកអ៊ាវ ហៅ ឌុច

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គឹមសួន
យុង ផានិត

Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ

François ROUX
MARIE-PAULE CANIZARES

គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN

Philippe CANNONE
ទី ស្រីនណា
Elizabeth RABESANDRATANA
Karim KHAN

យើង **និល ណុន** ប្រធាននៃអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ **កាំង ហ្គេកអ៊ាវ** ហៅ ឌុច ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបានបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ ("សេចក្តីសម្រេច")[1] ។

**បានឃើញ** សេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៩[2]

**បានឃើញ** ដីកាសម្រេចកំណត់កាលវិភាគសវនាការទៅតាមអង្គហេតុសម្រាប់ថ្ងៃទី ២០ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៩ ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ២០០៩[3]

**បានឃើញ** ដីកាសម្រេចកំណត់កាលវិភាគសវនាការទៅតាមអង្គហេតុសម្រាប់ថ្ងៃទី ១៨ ខែឧសភា ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៩ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩[4]។

**រំលឹកឡើងវិញថា** អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ទាក់ទងនឹងកាលវិភាគនៃដំណើរការសវនាការសម្រាប់រយៈពេលពីថ្ងៃទី ៣០ ខែមិថុនា ដល់ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០០៩ នៅក្នុងអំឡុងពេលសវនាការថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៩[5] ។

**បានឃើញ** ដីកាកំណត់ថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែបន្ទាប់ ចាប់ពីថ្ងៃទី ០៦ ខែកក្កដា ដល់ថ្ងៃទី ០១

---

[1] "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច" ថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ (ឯកសារ D99/3/42)។

[2] សេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៩ (ឯកសារលេខ E26)

[3] ដីកាសម្រេចកំណត់កាលវិភាគសវនាការទៅតាមអង្គហេតុសម្រាប់ថ្ងៃទី ២០ ដល់ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៩ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៩ (ឯកសារលេខ E48)

[4] ដីកាសម្រេចកំណត់កាលវិភាគសវនាការទៅតាមអង្គហេតុសម្រាប់ថ្ងៃទី ១៨ ខែឧសភា ដល់ថ្ងៃ ទី ២៥ ខែមិថុនា ឆ្នាំ ២០០៩ (ឯកសារ E56)

[5] កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការសវនាការថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៩។ កំណត់ហេតុប្រតិចារឹក ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០០៩ ទំព័រ ១ ដល់ ២

ខែតុលា ឆ្នាំ២០០៩ ចុះថ្ងៃទី ១២ ខែមិថុនា ឆ្នាំ២០០៩[6]

**បានឃើញ** សេចក្ដីសម្រេចលើសំណើសុំវិធានការការពារសាក្សី និងអ្នកជំនាញ និងលើសំណើរបស់ភាគី សុំស្ដាប់ចម្លើយសាក្សី និងអ្នកជំនាញ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០៩[7]។

**បានឃើញ** សេចក្ដីសម្រេចអំពីវិធានការការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី០២ ខែមិថុនា ២០០៩[8]។

**ដោយពិចារណាអំពី** ភាពចាំបាច់ក្នុងការជូនដំណឹងអោយបានគ្រប់គ្រាន់អំពីកាលបរិច្ឆេទសវនាការដល់ភាគីទាំងអស់ ក៏ដូចជាសាក្សីនិងអ្នកជំនាញដែលត្រូវធ្វើសក្ខីកម្ម។

## ហេតុដូច្នេះ

**សម្រេច** កំណត់កាលវិភាគនៃដំណើរការសវនាការលើអង្គសេចក្ដីសម្រាប់រយៈពេលពីថ្ងៃច័ន្ទទី១៣ ខែកក្កដា ដល់ថ្ងៃពុធទី ២៦ ខែសីហា ឆ្នាំ ២០០៩ ដូចខាងក្រោម៖

-ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៩៖ ស្ដាប់សក្ខីកម្មសាក្សី KW-08, KW-09 ទាក់ទងនឹងអង្គហេតុនៃការបង្កើតមន្ទីរម-១៣ អង្គហេតុនៃជម្លោះប្រដាប់អាវុធ និង ប្រតិបត្តិការមន្ទីរស២១រួមបញ្ចូលទាំងជើងឯក។

-ពីថ្ងៃទី ២០ ដល់ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០០៩៖ ស្ដាប់សក្ខីកម្មសាក្សី KW-10, KW-11 និង KW-07 ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការមន្ទីរស២១ រួមបញ្ចូលទាំងជើងឯក។

-នៅថ្ងៃទី ២៧ និង ២៨ ខែកក្កដា ឆ្នាំ២០០៩៖ ស្ដាប់សក្ខីកម្មសាក្សី KW-15 និង KW-20 ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការមន្ទីរស២១ រួមបញ្ចូលទាំងជើងឯក។

-ពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០០៩៖, ស្ដាប់សក្ខីកម្មសាក្សី KW-21, KW-22, KW-23

---

[6] ដីកាកំណត់ថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែបន្ទាប់(ចាប់ពីថ្ងៃទី០៦ ខែកក្កដា ដល់ថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៩)(ឯកសារE77)

[7] សេចក្ដីសម្រេចលើសំណើសុំវិធានការការពារសាក្សី និងអ្នកជំនាញ និងលើសំណើរបស់ភាគី សុំស្ដាប់ចម្លើយសាក្សី និងអ្នកជំនាញ ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០០៩ (ឯកសារលេខ E40)

[8] សេចក្ដីសម្រេចលើវិធានការការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០០៩ (ឯកសារE71)

និងអ្នកជំនាញ David Chandler ទាក់ទងនឹងអង្គហេតុនៃប្រតិបត្តិការមន្ទីរស២១ រួមបញ្ចូលទាំងជើង ឯក។

-នៅថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៩៖ ស្តាប់ចម្លើយអ្នករស់រានមានជីវិត KW-28 និង KW-29 ទាក់ទង នឹងអង្គហេតុនៃការបង្កើតនិងប្រតិបត្តិការមន្ទីរស-២៤។

-ពីថ្ងៃទី ១១ ដល់ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០០៩៖ ស្តាប់សក្ខីកម្មអ្នកជំនាញ CP2/5 បន្ទាប់មកស្តាប់ ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការទាមទារសំណង ហាវ សោភា (D25/4), នេត ផល្លី (E2/50), Robert Hamill (E2/87), Jeffrey James (E/86), ភុង ហ្គុតស៊ុនថារី (D25/5), អ៊ឹម ស៊ុន្ទី (D25/7), ជុំ ស៊ីរ៉ាត់ (D25/6), ឈិន ណារី (D25/2), គៀង វណ្ណារី (E2/77), ស៊ាង វ៉ាន់ឌី (D25/13), រស់ ម៉ែន (D25/9), តូច មុន្និន (D25/14), ជុំ នៅ (D25/16), E2/34, E2/81, D25/27, E2/82, E2/85, E2/89, អ៊ូ សាវរិត (E2/26)។

អង្គជំនុំជម្រះសាលាដំបូងសូមរក្សាសិទ្ធិក្នុងការកែប្រែកាលវិភាគនេះក្នុងករណីចាំបាច់។
ដីកាកំណត់កាលវិភាគបន្តបន្ទាប់ទៀតនៃដំណើការនីតិវិធី អង្គជំនុំជម្រះនឹងចេញក្នុងពេលសមស្រប។

ភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

និល - ណុន